# ការប្តូរ របប ?

នៅ អឺរ៉ុប សព្វថ្ងៃ មាន គ្រឹះស្ថាន មួយ ធ្វើ សកម្មភាព ចេញ មុខ ជួយ ដល់ ការតស៊ូ អហិង្សា របស់ ពួក អ្នក ប្រជាធិបតេយ្យ ប្រឆាំង នឹង របប ផ្តាច់ការ។ គ្រឹះស្ថាន នោះ ដើម ឡើយ ឈ្មោះ « Otpor ![1] » (កម្រាញ !) ជា កូន ក្រុម បង្កើត ដោយ យុវជន ស៊ែប (serbe) នៅ ឆ្នាំ ១៩៩៨។ គោលបំណង គឺ ដើម្បី រំលំ ប្រធានាធិបតី នៃ ប្រទេស យូហ្គោស្លាវី ឈ្មោះ Slobodan Miloševic។ ក្រុម នេះ ចាប់ ផ្តើម ល្បី ឈ្មោះ បន្ទាប់ ពី និស្សិត ៤ នាក់ ជា យុទ្ធកៈ របស់ Otpor ! ត្រូវ ប៉ូលិស នៃ របប Miloševic ចាប់ ខ្លួន រួច បញ្ជូន ទៅ តុលាការ ហើយ កាត់ ទោស ដាក់ ពន្ធនាគារ ចំនួន ១៥ ថ្ងៃ។ ក្រុម តូច នោះ មាន របៀប រៀបចំ និង ប្រតិបត្តិការ ជា បន្ទាត់ផ្តេក គ្មាន អ្នក ដឹកនាំ ជា ផ្លូវការ បង្ហាញ នូវ មធ្យោបាយ គ្រប់គ្រាន់ ដើម្បី ធ្វើ ឱ្យ របបនោះ ចុះ ខ្សោយ។ Otpor ! ប្រមូល ផ្តុំ យុវជន គ្រប់ និន្នាការ នយោបាយ លើក លែង តែ ពួក អ្នក កុម្មុយនិស្ត។ សកម្មភាព មិន ជា នយោបាយ ជ្រុល គ្រាន់ តែ ចង់ រំខាន ជា ល្បែង ដើម្បី ឱ្យ សាធារណជន សើច ចំអក ដល់ របប ផ្តាច់ការ។ គំរោង នយោបាយ ដ៏ សាមញ្ញ គឺ ស្វែង រក « ជីវភាព រស់នៅ ជា ធម្ម

[1] Otpor : La réistance, កម្រាញ។ ខ្ញុំ ប្រែ ពាក្យ បារាំង « résistance » ជា ភាសា ខ្មែរ ថា កម្រាញ គឺ ការក្រាញ ប្រឆាំង នឹង អ្វីមួយ។

តា » របស់ ប្រជាពលរដ្ឋ។ ដូច្នេះ ជា ការតស៊ូ ប្រឆាំង នឹង របប ដឹកនាំ ដែល ខាយាំង ប្រជាពលរដ្ឋ មិន ឱ្យ រស់នៅ បាន ជា មនុស្ស ធម្មតា។ ក្រោយ ពី ឆ្នាំ ១៩៩៩ នៅ ពេល ប្រទេស យូហ្គោស្លាវី មាន កើត សង្គ្រាម ស៊ីវិល និង អបគមន៍ ហើយ របប ផ្ដាច់ការ របស់ Miloševic ត្រូវ បាន យន្តហោះ របស់ OTAN ទម្លាក់ គ្រាប់ បែក នៅ ស៊ែប៊ី ដើម្បី ផ្ដន្ទាទោស ដល់ របប ផ្ដាច់ការ នោះ, មាន ជន រងគ្រោះ ជា ការ ទទួល ថ្មបាក់ គឺ ប្រជាជន ជា ទូទៅ ព្រោះ គ្រាប់បែក វា មិន ចេះ បែង ចែក រវាង ទាហាន របស់ Miloševic និង ជន ស្លូតត្រង់ នោះ ឡើយ។ ចាប់ ពី ពេល នោះ មក ពួក និស្សិត ជា សកម្មជន នៃ Otpor ! បោះ បង់ ឈ្មោះ ជា ក្រុម និស្សិត ដើម្បី ពង្រីក ក្រុម ទៅ ជា ចលនា តស៊ូ ប្រឆាំង នឹង របប ផ្ដាច់ការ។ ចលនា នេះ អំពាវនាវ ឱ្យ បង្កើត រណសិរ្ស រួម ជា កម្លាំង នយោបាយ ប្រឆាំង នឹង របប, ជា ចលនា ប្រមូល ផ្ដុំ គ្រប់ សាមាគមន៍, គណបក្ស នយោបាយ, ប្រព័ន្ធ ផ្សព្វផ្សាយ ឯករាជ្យ និង សហជីព។ ការពង្រីក នោះ ឯង ដែល ធ្វើ ឱ្យ Otpor ! ក្លាយ ជា ចលនា ខ្លាំងក្លា មួយ ប្រឆាំង នឹង របប Miloševic នៅ ពាក់ កណ្ដាល ឆ្នាំ ២០០០។ កម្លាំង នោះ ឯង ជួយ អោយ បាន ជោគជ័យ នៅ ពេល បោះ ឆ្នោត នៅ ថ្ងៃ ទី ២៧ កញ្ញា ឆ្នាំ ២០០០ គឺ គណបក្ស លោក Miloševic ទទួល បរាជ័យ។ ច្រើន ឆ្នាំ កន្លង មក ចលនា Otpor ! ដែល ក្លាយ ជា គណបក្ស នយោបាយ ហើយ បាន ចូល ធ្វើ សកម្មភាព ក្នុង រដ្ឋាភិបាល មិន ទទួល បាន ជោគជ័យ ច្រើន

## ការថ្នូរ ១៥៥

ដូច បំណង នោះ ឡើយ, ជា ពិសេស នៅ ក្នុង ការបោះឆ្នោត នៅ ឆ្នាំ ២០០៣ គណបក្ស ទទួល បាន សម្លេង តែ ១,៦% ពី ការជ្រើសរើស តែ ប៉ុណ្ណោះ។ បន្ទាប់ មក មេ ដឹកនាំ ពីរ នាក់ លោក Popovic និង Slobodan Dinovic បាន សំរេចចិត្ត បោះបង់ សកម្មភាព នយោបាយ ដើម្បី បង្កើត មជ្ឈមណ្ឌល ដើម្បី សកម្មភាព និង យុទ្ធសាស្ត្រ អហិង្សា ដែល មាន ឈ្មោះ កាត់ ថា « Canvas »។ មជ្ឈមណ្ឌល នេះ បង្ហាញ ខ្លួន ជា អង្គការ អប់រំ មិន មែន ជា អង្គការ នយោបាយ ហើយ ធ្វើ សកម្មភាព ផ្សាយ និង អប់រំ អំពី ការប៉ិនប្រសប់ (savoir-faire) របស់ ខ្លួន នៅ ក្នុង ប្រមាណ ៥០ ប្រទេស នៅ លើ ពិភពលោក។ អ្នក បង្ហាត់ របស់ Canvas បង្រៀន អំពី យុទ្ធសាស្ត្រ នៃ ការផ្លាស់ប្តូរ នៃ អំណាច ដឹកនាំ តាម វិធី អហិង្សា។ ពួក នោះ យល់ ច្បាស់ ណាស់ ថា វា គ្មាន បដិវត្តន៍ ដោយឯងៗ អាច មាន ជ័យជំនះ បាន នោះ ឡើយ។ ដើម្បី ទទួល បាន ជោគជ័យ ត្រូវ ចាំបាច់ មាន វិធាន ផែនការ និង កលយុទ្ធ ពិត ប្រាកដ ដូច យ៉ាង តើ ត្រូវ ធ្វើ ដូម្តេច ដើម្បី បង្កើត កង ឯកភាព, តឿន ឱ្យ មាន ការ មិន ស្តាប់បង្គាប់ ស៊ីវិល, រៀបចំ ធ្វើ ពហិការ ; ប្រើ ពាក្យស្លោក, ប្រើ ភ្លេង និង ចម្រៀង។ វិធី ទាំង នោះ រៀបចំ ឡើង ជា បួន ដំណាក់ការ : ការវិភាគ នៃ ស្ថានភាព, ការរចនា នៃ ប្រតិបត្តិការ (តើ ត្រូវ ធ្វើ បែប ណា), ការអនុវត្តន៍ (តើ ត្រូវ ធ្វើ ដូម្តេច ដើម្បី ឈ្នះ, អ្នក ណា ត្រូវ ធ្វើ អ្វីៗ មួយ, ធ្វើ នៅ ពេល ណា, ធ្វើ បែប ណា ហើយ ហេតុអ្វី ដែល ត្រូវ ធ្វើ ដូច្នោះ) ហើយ នៅ ទី

## ការប្តូរ របប

បញ្ចាប់ គឺ ដោះស្រាយ នូវ បញ្ហា បច្ចេកទេស (ការដឹកនាំ ភស្តុភា, ការសំរបសំរួល និង ការទំនាក់ទំនង)។ ត្រូវ រក ឱ្យ ឃើញ នូវ អត្តសញ្ញាណ នៃ វិសេសភាព នៃ ទីតាំង ដែល ជា មូលដ្ឋាន សំរាប់ ការពារ អំណាច ផ្តាច់ការ - នៅ ក្នុង ស្ថាប័ន ប៉ូលិស, កងទ័ព, ប្រព័ន្ធផ្សព្វផ្សាយ បំរើ របប ថា តើ នៅ ក្នុង នោះ អាចនឹង មាន អ្នក ដែល អាច ចូល រួម សកម្មភាព នៃ ការ មិន ស្តាប់បង្គាប់ ស៊ីវិល។ តែ Canvas បញ្ជាក់ ដោយ ច្បាស់លាស់ ថា ខ្លួន មិន ធ្វើ សហការ ដាច់ខាត ជា មួយ ក្រុម ជ្រុល និយម ព្រោះ ពួក នោះ គ្មាន លទ្ធភាព អាច នឹង បង្កើត កម្លាំង ដល់ ការ តស៊ូ អហិង្សា បាន នោះ ឡើយ។ ត្រូវ ដឹង ថា គោលវិធី ស៊ែប៊ី ឬ Canvas នេះ ត្រូវ បាន គេ យក ទៅ អនុវត្ត ជា ទ្រង់ទ្រាយ ធំ នៅ ប្រទេស អ៊ុយក្រែន នៅ ឆ្នាំ ២០០៣ ដើម្បី រំលំ របប ផ្តាច់ការ របស់ លោក Édouard Chevardnadze។ ចលនា នោះ មាន ឈ្មោះ ថា Kmara ! (Assez !) (ល្មម ហើយ !)។

### ប្រាជ្ញាផុស[2] អាមេរិកាំង

បន្ទាប់ ពី របប ផ្តាច់ការ Miloševic លោក ជីន សាប ( Gene Sharp) ជា នយៈវិទូ[3] អាមេរិកាំង (១៩២៨-២០១៨) ម្នាក់ បាន ធ្វើ ទស្សនាកិច្ច នៅ ប្រទេស ស៊ែប៊ី ហើយ លោក បាន ថ្លែង ថា :

[2] ប្រាជ្ញាផុស : Inspiration.
[3] នយៈវិទូ : អ្នកប្រាជ្ញ នយោបាយ។ Politiste.

វា ហាក់ បី សៀវភៅ[4] របស់ ខ្ញុំ មាន ឥទ្ធិពល ណាស់ នៅ ទី នេះ។ គោលទ្រឹស្តី របស់ លោក សាប ស្ថិត នៅ ក្នុង ក្រុម អ្នក យុទ្ធសាស្ត្រ តូច ផ្តុំ គ្នា នៅ មជ្ឈមណ្ឌល នៃ កិច្ចការ អន្តរជាតិ របស់ មហា វិទ្យាល័យ ដ៏ ល្បី មួយ នៅ សហរដ្ឋ អាមេរិ ឈ្មោះ Harvard ។ មជ្ឈមណ្ឌល នេះ បង្កើត ឡើង នៅ ឆ្នាំ ១៩៥៨ ដោយ លោក Thomas C. Schelling, Henry Kissinger, Edward Mason និង Robert R. Bowie។ នៅ ក្នុង មជ្ឈមណ្ឌល នោះ ដែរ ក៏ មាន ការ ចូលរួម ពី សំណាក់ ពួក អ្នក ទីប្រឹក្សា ល្បីៗ របស់ អ្នក ដឹកនាំ ដូច យ៉ាង លោក Zbigniew Brzezinski, Samuel P. Huntington និង Joseph Nye។ លោក Schelling ជា អ្នក សរសេរ អារម្ភកថា សៀវភៅ របស់ លោក ជិន សាប ដែល ជា សៀវភៅ ទទួល បាន រង្វាន់ វិទ្យាសាស្ត្រ សេដ្ឋកិច្ច[5] របស់ ធានាគារ នៃ ប្រទេស Suède ព្រោះ បាន ផ្តល់ នូវ គំនិត ដើម្បី ការ ធ្វើ ឲ ចម្រើន បន្ថែម អំពី ការ យល់ ដឹង នៃ យុត្តកម្ម នៃ ទំនាស់ និង សហការ តាម ការវិភាគ នៃ ទ្រឹស្តី នៃ ល្បែង។ ជា គំនិត មួយ សំរាប់ ការពារ « កិច្ចការ ទូត តាម ហិង្សា » :

[4] Gene Sharp, De la dictature à la démocratie. Un cadre pour la libération. Edition L'Harmattan, Paris 2009. សៀវភៅ មាន បក ប្រែ ជា ភាសា ខ្មែរ ដែល មាន ចំណង ជើង ថា ពី **របប ផ្តាច់ការ ទៅ ប្រជាធិបតេយ្យ តាម គោលគំនិត អហិង្សា**។ អ្នក បក ប្រែ គឺ លោក អ៊ឹង ប៊ុនអាង, លោក ជា សមាជិក ព្រឹទ្ធសភា, បោះពុម្ពលើកទី១ នៅ ឆ្នាំ ២០០២, លើក ទី២ ឆ្នាំ ២០០៣។

[5] ជា រង្វាន់ សំរាប់ រក្សា សតិ របស់ លោក Alfred Nobel។ រង្វាន់ នោះ មាន ឈ្មោះ រង្វាន់ ណូបែល នៃ សេដ្ឋកិច្ច។

**ភាគខ្មែរ ៖ខខខ**

អំណាច ព្យាបាទ គឺ ជា អំណាច ចរចា។ គំនិត នោះ ក៏ បាន ជំរុញ នូវ ការចាំបាច់ នៃ ការបង្ខំ មួយ ដែល វា លើស ពី ការ កំញើញ ទៅ ទៀត។

នៅ ឆ្នាំ ១៩៦៥ លោក ជិន សាប បាន ចូល ធ្វើ សហការ នៅ ក្នុង មជ្ឈមណ្ឌល នោះ ហើយ លោក បាន ចំណាយ ពេល វេលា របស់ លោក អស់ រយះពេល ៣០ ឆ្នាំ ដើម្បី សិក្សា ស្រាវជ្រាវ លើ ចលនា សង្គម នៅ ក្នុង បរិបទ នៃ សង្គ្រាម ត្រជាក់។ លោក យល់ ឃើញ ថា ការការពារ ប្រើ ជន ស៊ីវិល តាម ការតស៊ូ អហិង្សា ប្រហែល ជា អាច មាន ប្រសិទ្ធិភាព និង តម្លៃ តិច ជាង ការកំញើញ អាវុធ បរមាណូ ឬ ការ ធ្វើ សង្គ្រាម បវេណី ព្រោះ សកម្មភាព អហិង្សា បាញ់ ឆ្ពោះ ទៅ រក ប្រព័ន្ធ ផ្តាច់ការ អាច ប្រមូល ផ្តុំ ដោយ ប្រសិទ្ធិភាព បក្សពួក បាន ច្រើន ដើម្បី អង្រួន សសរគោល នៃ អំណាច ផ្តាច់ការ នៅ ក្នុង មហា វិទ្យាល័យ, កងទ័ព, ប៉ូលិស, ប្រព័ន្ធ ផ្សព្វផ្សាយ អោយ បន្ថយ ឬ ឈប់ គាំទ្រ របប ផ្តាច់ការ។ ទ្រឹស្តី របស់ លោក សាប ត្រូវ បាន លោក ឧត្តមសេនីយ William Westmoreland, មេបញ្ជាការ ជាន់ខ្ពស់ នៃ កងទ័ព អាមេរិកាំង នៅ យៀកណាម, យក មក កែឆ្នៃ ជា ទ្រឹស្តី សង្គ្រាម ប្រឆាំង នឹង កងទ័ព បដិវត្តន៍ យួន ហើយ អនុវត្ត នៅ ឆ្នាំ ១៩៦៤ នៅ ក្នុង សង្គ្រាម នៅ យៀកណាម ដោយ បញ្ចូល ទៅ ក្នុង យុទ្ធសាស្ត្រ យោធា បវេណី នូវ គោលវិធី : ចិត្ត សាស្ត្រ, នយោបាយ និង ប៉ុលិស។

នៅ ក្នុង គតិ របស់ លោក Reagan កាល លោក ជា ប្រធានាធិបតី អាមេរិកាំង « ជំរឿន នៃ ប្រជាធិបតី នៅ លើ ពិភពលោក» ត្រូវ បាន លោក សាប និង Schelling និង សហការី របស់ លោក មួយ ចំនួន បាន នាំ គ្នា បង្កើត មូលនិធិ សាធារណ: ដើម្បី ផ្តល់ ជំនួយ ហិរញ្ញវត្ថុ ដល់ ចលនា តស៊ូ អហិង្សា នៅ លើ ពិភពលោក តាម រយ: មូលស្ថាបនា ជាតិ ដើម្បី ប្រជាធិបតី (NED[6]) និង វិជ្ជាដ្ឋាន សាធារណរដ្ឋ អន្តរជាតិ (IRI[7])។

## បរិបទ ខ្មែរ

តើ អ្នក ប្រជាធិបតេយ្យ និង គណបក្ស ប្រឆាំង ខ្មែរ ស្គាល់ ទ្រឹស្តី និង គោលវិធី របស់ លោក ជិន សាប និង Canvas ដែរ ឬ ទេ ? ចម្លើយ គឺ ថា ពិត ជា ស្គាល់ ច្បាស់ ណាស់។ ដូច យ៉ាង ទ្រឹស្តី លោក ជិន សាប បាន លើក មក ធ្វើ វិភាគ និង សិក្សា ជា មេរៀន នៅ ក្នុង សាលា សង្គ្រាម នយោបាយ នៃ សាធារណរដ្ឋ ខ្មែរ (១៩៧០-៧៥) នៅ ក្នុង ផ្នែក សង្គ្រាម ចិត្តសាស្ត្រ ប្រឆាំង នឹង កងទ័ព យួន កុម្មុយនិស្ត និង ខ្មែរ ក្រហម។ នៅ សម័យ សាធារណរដ្ឋ ខ្មែរ ពួក កុម្មុយនិស្ត យួន និង ខ្មែរ ប្រើ សង្គ្រាម ចិត្តសាស្ត្រ វាយ ប្រហារ ចូល ទៅ ក្នុង មជ្ឈដ្ឋាន គ្រូបង្រៀន, និស្សិត, សិស្សសាលា, កងទ័ព, ប្រព័ន្ធផ្សព្វផ្សាយ និង សហជីព ទទួល បាន ជ័យជំនះ ជាក់ស្តែង ព្រោះថា កម្លាំង នយោបាយ

---

[6] Fondation nationale pour la démocratie.
[7] Institut républicain international.

វាយ ប្រហារ សាធារណរដ្ឋ ខ្មែរ គឺ ចេញ ពី ប្រភព នោះ ឯង រហូត ធ្វើ ឱ្យ បែកបាក់ រវាង កងទ័ព និង នយ:ជន[8] ជំៗ តែ ម្តង។

ដូច បាន សរសេរ ពី ខាង លើ រួច មក ហើយ ថា សៀវភៅ លោក ជិប មាន បកប្រែ ជា ភាសា ខ្មែរ តាំង ពី ឆ្នាំ ២០០២ មក ម្លេះ ដូច្នេះ គំនិត តស៊ូ តាម វិធី អហិង្សា វា មាន នៅ គតិ ពួក នយ:ជន ខ្មែរ ដែល ជា អ្នក ប្រជាធិបតេយ្យ ជា យូរ ណាស់ ហើយ ដែរ។ ដូច្នេះ ពួក អ្នក ដឹកនាំ គណបក្ស ប្រឆាំង សុទ្ធ តែ បាន សិក្សា អំពី គោលវិធី អហិង្សា ហើយ យក វា មក អនុវត្ត នៅ ក្នុង សកម្មភាព នយោបាយ ដូច យ៉ាង គណបក្ស សង្គ្រោះជាតិ ហើយ ទទួល បាន ជ័យជំនះ ជាក់ស្តែង នៅ ឆ្នាំ ២០១៣ តែ ពួក អ្នក ផ្តាច់ការ កែក្រឡៃ លទ្ធផល បោះឆ្នោត ទុក ខ្លួន ជា អ្នក ឈ្នះ ដើម្បី រក្សា អំណាច។

គ្រឹះស្ថាបនា នៃ ជ័យជំនះ របស់ គណបក្ស សង្គ្រោះជាតិ នៅ ឆ្នាំ ២០១៣ គឺ ការប្រមូល ផ្តុំ អ្នក ប្រជាធិបតេយ្យ ឱ្យ មក រួម គ្នា នៅ ក្នុង គណបក្ស ប្រឆាំង តែ មួយ ដើម្បី ចូលរួម បោះឆ្នោត។ តែ ទុព្វលភាព របស់ សង្គ្រោះជាតិ នៅ ពេល នោះ គឺ បែរ ត្រឡប់ មក លេង ល្បែង នយោបាយ របស់ របប ផ្តាច់ការ គឺ សុខចិត្ត រស់នៅ នៅ ក្នុង ស្ថានភាព ជា « អ្នក ឈ្នះ រស់ ជា អ្នក ចាញ់ » នៅ ក្នុង រដ្ឋសភា។ ប៉ុន្តែ ជ័យជំនះ ជា ការចម្រើន ចំនួន អាសនៈ របស់ គណបក្ស សង្គ្រោះជាតិ ក្នុង ការបោះ

---

[8] នយ:ជន : អ្នកនយោបាយ។

ឆ្នោត មូលដ្ឋាន រើស ទីប្រឹក្សា ភូមិ-សង្កាត់[9] នៅ ខែ មីនា ឆ្នាំ ២០១៧ នៅ តែ រក្សា ជំហរ គណបក្ស ជា អ្នក ប្រឆាំង ដាច់ខាត នឹង របប ផ្តាច់ការ ទោះ បី ត្រូវ មតិខ្មែរ មួយ ចំនួន ចោទ ប្រកាន់ អ្នក ដឹកនាំ គណបក្ស ថា ក្បត់ ឆន្ទៈ អ្នក បោះឆ្នោត ព្រោះ សុខចិត្ត ចូល រួមប្រជុំ ក្នុង រដ្ឋសភា អជម្មនុញ្ញ។ ការ ចម្រើន ចំនួន អាសនៈ ឃុំ-សង្កាត់ នោះ ឯង តម្រូវ ឱ្យ របប ផ្តាច់ការ ស្វែង រក ល្បិច ឬ ល្បែង នយោបាយ ថ្មី ដើម្បី ការពារ អំណាច នៅ ពេល បោះឆ្នោត សាកល នៅ ឆ្នាំ ២០១៨ ព្រោះ ដឹង ច្បាស់ ថា ជ័យជំនះ របស់ ខ្លួន ពីមុនៗ មក ជា ការឈ្នះ បាន មក ពី ការលួច សន្លឹក ឆ្នោត នោះ ឯង។ ដូច យើង ដឹង ស្រាប់ ហើយ ល្បែង ថ្មី គឺ រំលាយ គណបក្ស សង្គ្រោះជាតិ[10] និង ចាប់ កឹម សុខា ដាក់ ពន្ធនាគារ[11] ដើម្បី ធ្វើ ការបោះឆ្នោត ក្លែងក្លាយ យក ឈ្នះ មិន ចាំបាច់ ប្រកួត ដោយ យល់ ឃើញ ថា ល្បិច នេះ នឹង អាច បំបែក បំបាក់ គណបក្ស សង្គ្រោះជាតិ បាន។

បទ ចោទ ប្រកាន់ កឹម សុខា គឺ ទំនាក់ ទំនង ជាមួយ បរជន ជា ជនជាតិ អាមេរិកាំង នៅ ឆ្នាំ ២០១៣ ដើម្បី បង្កចលាចល បំផ្លាញ សន្តិភាព តាម យុទ្ធសាស្រ្ត នយោបាយ ដើម្បី រំលំ រាជរដ្ឋាភិបាល។ ការចោទប្រកាន់ គឺ សំអាង លើ vidéo ចាស់ មួយ

9 ឈ្នះ ចំនួន អាសនៈ ៤៨២។ គណបក្ស ប្រជាជន ឈ្នះ ចំនួន អាសនៈ ១១៦៣។

10 ខែ វិច្ឆិកា ឆ្នាំ ២០១៧។

11 ថ្ងៃទី៣ កញ្ញា ឆ្នាំ ២០១៧។ បទចោទប្រកាន់ ធ្វើ សកម្មភាព ក្បត់ ជាតិ ជា មួយ បរជន ដើម្បី រំលំ រាជរដ្ឋាភិបាល។

ថត នៅ ឆ្នាំ ២០១៣ នៅ ក្នុង នោះ មាន កឹម សុខា កំពុង និយាយ ថា គាត់ ធ្លាប់ បាន សិក្សា ទ្រឹស្តី ការតស៊ូ អហិង្សា ប្រឆាំង នឹង អំណាច ផ្តាច់ការ (sic)។ ទ្រឹស្តី នោះ គ្មាន អ្វី ក្រៅ ពី ទ្រឹស្តី លោក ជិន សាប និង ពួក Canvas នោះ ឡើយ។ សម រង្ស៊ី បច្ចុប្បន្ន ធ្វើ សកម្មភាព នៅ ក្នុង វង់ គំនិត នៃ ទ្រឹស្តី ជិន សាប នោះ ដែរ ដែល ជា ទ្រឹស្តី ក្លាយ ជា មូលដ្ឋាន នៃ គំនិត នយោបាយ សាកល នៃ ការតស៊ូ អហិង្សា ប្រឆាំង នឹង អំណាច ផ្តាច់ការ។ តែ ក្នុង គតិ សម រង្ស៊ី ក្តី កឹម សុខា ក្តី គឺ ធ្វើ ការតស៊ូ ដើម្បី ជំរឿន នៃ ប្រជាធិបតី នៅ កម្ពុជា។ នយៈជន ទាំង នោះ ត្រូវ ចាំបាច់ ស្គាល់ និង សិក្សា គ្រប់ ទ្រឹស្តី នយោបាយ, សួរថា តើ វា ជា បទឧក្រិដ្ឋ គ្រាន់ តែ ទាមទារ តាម សន្តិវិធី ឱ្យ មាន ការ បោះឆ្នោត ដោយ យុត្តិធម៌ និង សេរី? រហូត ចោទ ប្រកាន់ សម រង្ស៊ី និង កឹម សុខា ថា ជា ជន ក្បត់ជាតិ, តើ វា មាន តក្កភាព (logique) ដែរ ឬ ទេ ?

ការសិក្សា ខាង លើ នេះ ផ្អែក លើ ឯកសារ យោង : Le monde diplomatique n° Décembre 2019 – Article : Changements de régime clés en main.